# របាយការណ៍បញ្ចប់ស្តីពីការដោះស្រាយវិវាទ*

# គម្រោងអាកាសយានដ្ឋាន ២ ក្នុងប្រទេសកម្ពុជា ខែឧសភា ឆ្នាំ២០១៥

*របាយការណ៍នេះ សង្ខេបអំពីដំណើរការដោះស្រាយវិវាទរបស់ការិយាល័យភាពអនុលោម ទីប្រឹក្សា អ្នកដោះស្រាយវិវាទ (CAO) ទាក់ទងទៅនឹងពាក្យបណ្តឹងដែលបានប្តឹងពាក់ព័ន្ធនឹងគម្រោងអាកាសយានដ្ឋាន ២ ក្នុងប្រទេសកម្ពុជា (#25332) ក្នុងខេត្តព្រះសីហនុ ប្រទេសកម្ពុជា។*

## សង្ខេបអំពីពាក្យបណ្តឹង និងដំណើរការរបស់ការិយាល័យ CAO

ក្រុមហ៊ុន Societe Concessionaire de l'Aeroport (SCA) ដែលជាក្រុមហ៊ុនមួយមានគោលបំណងពិសេស ទទួលបានសម្បទានរយៈពេល៤៥ឆ្នាំ ពីរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើប្រតិបត្តិការអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ អាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាប និង អាកាសយានដ្ឋានខេត្តព្រះសីហនុ។ IFC មានគម្រោងចំនួនពីរជាមួយក្រុមហ៊ុន SCA គម្រោងទី២ ពាក់ព័ន្ធទៅនឹងការផ្តល់ហិរញ្ញប្បទានសម្រាប់ចំណាយមូលធន និង ការវិនិយោគទៅលើផ្លូវ runway សម្រាប់អាកាសយានដ្ឋានខេត្តព្រះសីហនុ[1]។

ក្នុងខែធ្នូ ឆ្នាំ២០០៩ អង្គការមិនមែនរដ្ឋាភិបាលជាតិមួយក្នុងប្រទេសកម្ពុជា បានដាក់ពាក្យបណ្តឹងទៅកាន់ការិយាល័យ CAO ជំនួសឱ្យប្រជាពលរដ្ឋចំនួន៧៩ គ្រួសារ ដែលជឿថា ពួកគេបានរងផលប៉ះពាល់អវិជ្ជមានពីគម្រោងអាកាសយានដ្ឋាន ២ ក្នុងប្រទេសកម្ពុជារបស់ IFC។ ពួកគេបានអះអាងថា គម្រោងពុំមានភាពអនុលោមទៅនឹងល័ក្ខខ័ណ្ឌតម្រូវរបស់ IFC។ គ្រួសារដើមបណ្តឹងរស់នៅក្បែរទីតាំងគម្រោង ហើយគ្រួសារជាច្រើនមានកម្មសិទ្ធិដីធ្លីនៅក្នុងកន្លែង ដែលគេសន្និដ្ឋានថាជាតំបន់ពង្រីកអាកាសយានដ្ឋានរបស់គម្រោង។



ប្រជាពលរដ្ឋក្នុងមូលដ្ឋានកំពុងធ្វើស្រែលើដីកសិកម្ម (តំបន់ខ)
ក្បែរអាកាសយាន្តដ្ឋានខេត្តព្រះសីហនុ

ដើមបណ្តឹងបានលើកឡើងនូវការព្រួយបារម្ភមួយចំនួនអំពីការធ្វើលទ្ធកម្មដីធ្លី និងការផ្តល់សំណងមិនសមស្រប ការបាត់បង់ជីវភាពរស់នៅ ការបំពុលបរិស្ថានដោយសម្លេង ផលប៉ះពាល់បរិស្ថានទៅលើឧទ្យានជាតិមួយ ការចាត់ចំណាត់ថ្នាក់ផ្នែកបរិស្ថាន និងសង្គមដោយ IFC មិនបានត្រឹមត្រូវ កង្វះការពិគ្រោះយោបល់ជាមួយសហគមន៍ និង ការបើកចំហព័ត៌មានគម្រោងមិនបានគ្រប់គ្រាន់ ជូនដល់សហគមន៍រងផលប៉ះពាល់។ ការិយាល័យ CAO បានកំណត់ថា ពាក្យបណ្តឹងមានល័ក្ខខ័ណ្ឌសមស្របដើម្បីចុះធ្វើការវាយតម្លៃ ក្នុងខែមករា ឆ្នាំ២០១០ ហើយរបាយ

[1] សម្រាប់ព័ត៌មានបន្ថែមអំពីគម្រោងរបស់ IFC អាចរកបាននៅតាមគេហទំព័ររបស់ IFC : https://goo.gl/utt8lo និង http://goo.gl/vQq8WX

ការណ៍វាយតម្លៃ មួយត្រូវបានផ្សព្វផ្សាយជាសាធារណៈ ក្នុងខែសីហា ឆ្នាំ២០១០។

បើទោះបីជាភាគីបានយល់ព្រមព្យាយាមដោះស្រាយបញ្ហា នៅក្នុងពាក្យបណ្ដឹង តាមរយៈដំណើរការដោះស្រាយវិវាទ បែបសហការមួយ ដែលផ្ដួចផ្ដើមរៀបចំឡើងដោយ ការិយាល័យ CAO ក៏ដោយ ប៉ុន្តែ ពួកគេមិនអាចជួបគ្នាផ្ទាល់ នៅក្នុងវេទិកាសន្ទនាពហុភាគីអ្នកពាក់ព័ន្ធរួមគ្នាមួយបានឡើយ។ ដូច្នេះ ក្រុមការងាររបស់ការិយាល័យ CAO បានរៀបចំឱ្យមានការច្របាច់បញ្ចូលគ្នាមួយ នូវកិច្ចប្រជុំដោយឡែក និង "យន្តការអន្តរការី" ដើម្បីជួយដល់ភាគីក្នុងការដោះស្រាយបញ្ហា។ "ភាគី" ក្នុងករណីនេះ រួមមាន ដើមបណ្ដឹង និង សមាជិកសហគមន៍ដទៃទៀតដែលរងផលប៉ះពាល់ អង្គការមិនមែនរដ្ឋាភិបាល និង អង្គការសង្គមស៊ីវិល តំណាងនានារបស់រដ្ឋាភិបាល ក្រុមហ៊ុន SCA និង IFC។

ក្នុងអំឡុងពេលនៃការត្រួតពិនិត្យរបស់ការិយាល័យ CAO ទៅលើការប្ដេជ្ញាចិត្តដែលត្រូវបានធ្វើឡើងនៅក្នុងដំណើរការនេះ សហគមន៍មូលដ្ឋាន ដែលរស់នៅតាមបណ្ដោយរបងអាកាសយានដ្ឋាន បានលើកឡើងនូវការព្រួយបារម្ភអំពី ការផ្លាស់ប្ដូរមួយចំនួនដែលធ្វើឡើងដោយក្រុមហ៊ុន SCA ចំពោះព្រំប្រទល់របងខាងក្នុង ដែលបណ្ដាលឲ្យបញ្ហាជន់លិច និងប្រព័ន្ធបង្ហូរទឹកមានការកើនឡើងតាមបណ្ដោយរបងអាកាសយានដ្ឋាន។ ការិយាល័យ CAO លើកទឹកចិត្តឲ្យក្រុមហ៊ុន SCA និងសមាជិកសហគមន៍រងផលប៉ះពាល់ធ្វើការងារជាមួយគ្នា និងធ្វើការងារជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីស្វែងរកដំណោះស្រាយដែលអាចទទួលយកបាន ទាំងសងខាង។

ក្នុងខែកុម្ភៈ ឆ្នាំ២០១៥ ការិយាល័យ CAO បានរៀបចំកិច្ចប្រជុំបញ្ចប់គម្រោងលើកចុងក្រោយមួយ ក្នុងខេត្តព្រះសីហនុជាមួយដើមបណ្ដឹងដំបូងចំនួន២២នាក់ និងអង្គការមិនមែនរដ្ឋាភិបាលដែលបានជួយដល់សហគមន៍នៅក្នុងដំណើរការទាំងមូល ដែលរួមមានជាអាទិ៍៖ អង្គការអភិរក្ស និងអភិវឌ្ឍន៍កម្ពុជា (CDCAM) អង្គការស្រាវជ្រាវជាតិកម្ពុជា (CNRO) និង វេទិកាអង្គការក្រៅរដ្ឋាភិបាលស្ដីពីកម្ពុជា។ អ្នកចូលរួមបានផ្ដល់មតិយោបល់ត្រឡប់ជូនដល់ការិយាល័យ CAO អំពីដំណើរការ និងបានបញ្ជាក់ថាបញ្ហាបណ្ដឹងត្រូវបានដោះស្រាយក្នុងលក្ខណៈមួយគួរជាទីពេញចិត្តចំពោះពួកគេ។

## លទ្ធផល

### (១) ផលប៉ះពាល់ទៅលើជីវភាពរស់នៅ និងបទដ្ឋានជីវិតរស់នៅ ការវាយតម្លៃដីធ្លី និងសំណង

ដូចមានកត់សម្គាល់ នៅក្នុងរបាយការណ៍វាយតម្លៃរបស់ការិយាល័យ CAO សមាជិកសហគមន៍ មានការព្រួយបារម្ភយ៉ាងខ្លាំង អំពីផលប៉ះពាល់ដែលអាចកើតមានបណ្ដាលមកពីគម្រោងអាកាសយានដ្ឋាននេះ និង ផលប៉ះពាល់បណ្ដាលមកពីការតាំងទីលំនៅថ្មីទៅលើជីវភាពរស់នៅ និង បទដ្ឋានជីវិតរស់នៅរបស់ពួកគេ។ ពួកគេក៏មានបំណងចង់ធានាឱ្យមានដំណើរការមួយប្រកបដោយភាពយុត្តិធម៌ផងដែរ។ តាមរយៈដំណើរការរបស់ការិយាល័យ CAO ភាគីសម្រេចបានលទ្ធផលការងារ ដូចតទៅ ៖

- ផែនការសកម្មភាព ស្ដីពីការដោះស្រាយផលប៉ះពាល់ (RAP) ត្រូវបានរៀបចំសេចក្ដីព្រាង និងបញ្ចប់រួចរាល់។ រាជរដ្ឋាភិបាលកម្ពុជា បានប្ដេជ្ញាធ្វើឱ្យមានភាពអនុលោមទៅនឹងស្តង់ដារសមិទ្ធិកម្មរបស់ IFC ហើយ IFC ត្រូវបានផ្ដល់ឱកាសឲ្យផ្ដល់យោបល់ទៅក្នុងការរៀបចំសេចក្ដីព្រាង RAP នេះ។
- គិតត្រឹមពេលដែលកំពុងសរសេររបាយការណ៍នេះ មានប្រជាពលរដ្ឋចំនួន១៩១គ្រួសារ ត្រូវបានផ្ដល់សំណង[2]៖
  - ប្រជាពលរដ្ឋចំនួន១៥៧គ្រួសារ បានទទួលសំណងហិរញ្ញវត្ថុប៉ុណ្ណោះ

---

2 ទិន្នន័យផ្ដល់ដោយក្រុមហ៊ុន Green Goal និងបញ្ជាក់ដោយអង្គការ CDCAM និង CNRO។

– ប្រជាពលរដ្ឋចំនួន៣៤គ្រួសារ បានទទួលសំណងហិរញ្ញវត្ថុ និងដីថ្មី។ នៅក្នុងទស្សនកិច្ចត្រួតពិនិត្យតាមដានមួយរបស់ CAO ទៅកាន់សហគមន៍ទឹកសាបមានជ័យ ដែលត្រូវបានរៀបចំសម្រាប់ការតាំងទីលំនៅថ្មី តំណាងសហគមន៍ដែលត្រូវបានបោះឆ្នោតជ្រើសរើស បានរាយការណ៍ឱ្យដឹងថា "យើងខ្ញុំមានភាពសប្បាយរីករាយខ្លាំងណាស់នៅទីនេះ។ ទីនេះប្រសើរជាងកន្លែងដែលយើងរស់នៅពីមុន"។

- រាជរដ្ឋាភិបាលកម្ពុជា បានចាប់ដៃគូការងារជាមួយ ក្រុមហ៊ុន Green Goal (ក្រុមហ៊ុនពិគ្រោះយោបល់មួយរបស់ខ្មែរ ដែលត្រូវបានជួលដើម្បីជួយដល់ការងារដោះស្រាយផលប៉ះពាល់) និង អង្គការអភិរក្ស និង អភិវឌ្ឍន៍កម្ពុជា ដែលជាអង្គការមិនមែនរដ្ឋាភិបាលមួយដែលបានជួយ និង ផ្តល់ដំបូន្មានដល់សហគមន៍ដែលបានដាក់ពាក្យបណ្តឹង ឱ្យអនុវត្តកម្មវិធីស្តារប្រាក់ចំណូលឡើងវិញ។ កម្មវិធីនេះ រួមមាន៖

១. ផ្តល់ការអប់រំសុខភាពសម្រាប់សហគមន៍
២. ផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ
៣. កំណត់រកប្រភេទអាជីវកម្មសម្រាប់ការបង្កើតប្រាក់ចំណូល
៤. រៀបចំកិច្ចប្រជុំសហគមន៍ឱ្យបានទៀងទាត់ និង
៥. បង្កើតផែនការអភិវឌ្ឍន៍សហគមន៍មួយ និងផ្តល់ជំនួយសម្រាប់ការអនុវត្តន៍ ការគ្រប់គ្រង និងនិរន្តរភាព។

### (២) ការទទួលបានព័ត៌មានគម្រោង និងសម្លេងរបស់សហគមន៍មូលដ្ឋាននៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត

សហគមន៍បានរាយការណ៍ឱ្យការិយាល័យ CAO បានដឹងថាពួកគេត្រូវការព័ត៌មានអំពីគម្រោង និង ផែនការដោះស្រាយផលប៉ះពាល់ឱ្យបានទាន់ពេលវេលា ដើម្បីឱ្យពួកគេអាចព្យាករណ៍ទុកជាមុនបានខ្លះ សម្រាប់ចាត់ចែងការងារផ្ទាល់ខ្លួនរបស់ពួកគេ រក្សាបាននូវជីវភាពរស់នៅ និង ទទួលបានសេចក្តីត្រូវការមូលដ្ឋានប្រចាំថ្ងៃរបស់ពួកគេ។ ពួកគេក៏ចង់បានឱកាសមួយ ដើម្បីជះឥទ្ធិពលទៅលើសេចក្តីសម្រេចចិត្តនានា ដែលបង្កឱ្យមានផលប៉ះពាល់ទៅលើពួកគេផងដែរ។ ភាគីសម្រេចបាននូវលទ្ធផលមួយចំនួន នៅក្នុងចំណុចនេះ ៖

- គណៈកម្មការលទ្ធកម្មដីធ្លី (LC) នៃទីស្តីការគណៈរដ្ឋមន្ត្រី បានជួលក្រុមហ៊ុន Green Goal ឱ្យជួយដល់ការអនុវត្តន៍ផែនការសកម្មភាពស្តីពីការដោះស្រាយផលប៉ះពាល់ និងជាពិសេស គឺកម្មវិធីស្តារប្រាក់ចំណូលឡើងវិញ។ ក្រុមហ៊ុន Green Goal បានចាប់ផ្តើមកិច្ចសហប្រតិបត្តិការជាមួយអង្គការអភិរក្ស និង អភិវឌ្ឍន៍កម្ពុជា។ ក្រុមហ៊ុន Green Goal និងអង្គការអភិរក្ស និង អភិវឌ្ឍន៍កម្ពុជា បានរួមគ្នារៀបចំវគ្គពិគ្រោះយោបល់មួយចំនួន ដើម្បីរៀបចំត្រៀមលក្ខណៈគ្រួសាររងផលប៉ះពាល់ មុនពេលចាកចេញទៅរស់នៅទីតាំងថ្មី ព្រមទាំងរៀបចំផែនការសហគមន៍រួមគ្នា នៅឯកន្លែងតាំងទីលំនៅថ្មី។

- សិក្ខាសាលាអប់រំ ត្រូវបានរៀបចំធ្វើឡើងដោយក្រុមហ៊ុន Green Goal និង អង្គការ CDCAM សម្រាប់សហគមន៍តាំងទីលំនៅថ្មី អំពីប្រធានបទដូចខាងក្រោម ៖

១. ប្រព័ន្ធទឹកសាប
២. រដ្ឋបាលសហគមន៍ ឥណទាន និងការរៀបចំផែនការ

## ៣. ការស្តារជីវភាពរស់នៅឡើងវិញ

- ខិត្តប័ណ្ណព័ត៌មាន និង សេចក្តីសង្ខេបផែនការសកម្មភាពស្តីពីការដោះស្រាយផលប៉ះពាល់ មានផ្តល់ជូននៅពេលមួយ នៅឯ "មជ្ឈមណ្ឌលព័ត៌មានសាធារណៈ" របស់អាកាសយានដ្ឋាន ប៉ុន្តែក្រោយមក ភាគីបានរកឃើញវិធីដែលកាន់តែមានប្រសិទ្ធភាពជាងនេះ ក្នុងការប្រាស្រ័យទាក់ទង និង ផ្តល់ព័ត៌មានតាមរយៈបណ្តាញមិនផ្លូវការក្នុងមូលដ្ឋាន (សាលាឃុំ[3] អង្គការមិនមែនរដ្ឋាភិបាល ក្រុមហ៊ុន Green Goal កិច្ចប្រជុំសហគមន៍ ។ល។)
- បណ្តឹងសារទុក្ខត្រូវបានដោះស្រាយតាមរយៈការពិគ្រោះយោបល់ ដែលត្រូវបានធ្វើឡើងនៅ៣កម្រិត គឺថ្នាក់ឃុំ រដ្ឋាភិបាលថ្នាក់ខេត្ត និង គណៈកម្មការលទ្ធកម្មដីធ្លី (ឧ. ទាក់ទងទៅនឹងកម្មសិទ្ធិដីធ្លីចំនួនប្រាក់សំណង ការប្រើប្រាស់ដី ។ល។)។



ប្រព័ន្ធផ្គត់ផ្គង់ទឹកនៅឯកន្លែងតាំងទីលំនៅថ្មី "សហគមន៍អភិវឌ្ឍន៍ទឹកសាបមានជ័យ"

### មេរៀន និងខ្លឹមសារស៊ីជម្រៅ

**បង្គលក្ខណៈឱ្យមានការចូលរួមពីរាល់ភាគីពាក់ព័ន្ធសំខាន់ៗ**

វាបានបង្ហាញឱ្យឃើញយ៉ាងច្បាស់តាំងពីដំបូង នៅក្នុងការវាយតម្លៃទៅលើករណីនេះថា ដើមបណ្តឹង (សមាជិកសហគមន៍មូលដ្ឋាន) ក្រុមហ៊ុន SCA និង IFC មិនអាចដោះស្រាយបញ្ហាទាំងនេះតែឯងបានឡើយ។ រាជរដ្ឋាភិបាលបានបញ្ជាក់យ៉ាងច្បាស់លាស់ថា ពួកគេជាអ្នកទទួលបន្ទុកដំណើរការដោះស្រាយផលប៉ះពាល់។ អង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដែលបានជួយដល់សហគមន៍ក្នុងការដាក់ពាក្យបណ្តឹងទៅកាន់ការិយាល័យ CAO បានចូលរួមយ៉ាងសកម្មក្នុងការត្រួតពិនិត្យទៅលើគម្រោង និងផ្តល់ដំបូន្មានដល់ដើមបណ្តឹង ហើយដំណោះស្រាយមួយមិនអាចសម្រេចទៅបានឡើយ ប្រសិនបើពុំមានការចូលរួម និងការប្រឹងប្រែងរបស់ពួកគេទេនោះ។ តំណាងរដ្ឋាភិបាល

[3] ឃុំ គឺជាការបែងចែករដ្ឋបាលកម្រិតទី៣ នៅក្នុងប្រទេសកម្ពុជា។ ឃុំស្ថិតនៅក្រោមស្រុក និង រួមមានភូមិជាច្រើនក្នុងនោះ។

ថ្នាក់ខេត្ត ក៏ដើរតួនាទីសំខាន់ផងដែរ។ ដូច្នេះ ក្រុមការងារនៃការិយាល័យ CAO បានឈោងចាប់ដើម្បីធ្វើការប្រាស្រ័យទាក់ទងជាមួយភាគីទាំងអស់នេះបន្ថែមទៀត ហើយពួកគេសុទ្ធសឹងតែបានយល់ព្រមធ្វើការងារជាមួយការិយាល័យ CAO នៅក្នុងដំណើរការដោះស្រាយវិវាទមួយបែបសហការ ដើម្បីខិតខំដោះស្រាយបញ្ហាទាំងនេះ។ ដោយសារតែមានការពឹងផ្អែកគ្នាទៅវិញទៅមក ក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់នេះ ជុំវិញបញ្ហាបណ្ដឹងនេះ ដូច្នេះ វាមិនទំនងថាដំណើរការនេះ អាចទទួលបានជោគជ័យឡើយ ប្រសិនបើពុំមានកិច្ចសហប្រតិបត្តិការ និង ការចូលរួមពីពួកគេទេនោះ។

## ត្រូវមានភាពបត់បែនទន់ភ្លន់ចំពោះជម្រើសដំណើរការដោះស្រាយវិវាទ

នៅពេលដែលភាគី និង អ្នកពាក់ព័ន្ធសំខាន់ៗមួយចំនួនមិនអាច ឬ គ្មានឆន្ទៈក្នុងការចូលរួមធ្វើការងារជាមួយគ្នាដោយផ្ទាល់ ប៉ុន្តែ ពួកគេចាប់អារម្មណ៍ក្នុងការព្យាយាមដោះស្រាយបញ្ហាពាក្យបណ្ដឹង តាមរយៈដំណើរការដោះស្រាយវិវាទមួយ ក្រុមការងារនៃការិយាល័យ CAO បានត្រៀមខ្លួនរួចជាស្រេច ដើម្បីជួយដល់ភាគីក្នុងលក្ខណៈមួយប្រកបដោយភាពច្នៃប្រឌិត និង មានភាពបត់បែនទន់ភ្លន់។ ក្នុងករណីនេះ ក្រុមការងារនៃការិយាល័យ CAO រាប់បញ្ចូលអ្នកសម្របសម្រួលជនជាតិខ្មែរក្នុងស្រុកម្នាក់ បានប្រើប្រាស់ការច្របាច់បញ្ចូលគ្នាមួយនូវកិច្ចប្រជុំដោយឡែកពីគ្នា និង "យន្តការអន្តរការី" ដើម្បីជួយដល់ភាគីក្នុងការដោះស្រាយបញ្ហាទាំងនោះ។ ដូច្នេះ ខណៈពេលដែលពុំមានដំណើរការសម្របសម្រួល ឬ កិច្ចសន្ទនាជាផ្លូវការ ការិយាល័យ CAO បានប្រើប្រាស់ "ការិយាល័យដ៏ល្អ" និងអព្យាក្រឹត្យ ព្រមទាំងជំនាញឯកទេសផ្នែកដោះស្រាយវិវាទរបស់ខ្លួន ដើម្បីសម្របសម្រួលឱ្យមានការប្រាស្រ័យទាក់ទងដោយប្រយោល និង មិនផ្លូវការ។ ទង្វើបែបនេះបានជួយបញ្ជាក់អំពីបញ្ហាមួយចំនួន ស្វែងរកប្រធានបទដែលភាគីមានការព្រួយបារម្ភរួមគ្នា កាត់បន្ថយភាពតានតឹង និង ទីបំផុតឈានទៅធ្វើការដោះស្រាយសេចក្ដីត្រូវការដែលសំខាន់បំផុតរបស់ភាគី។

ស្របពេលជាមួយគ្នានោះ យន្តការអន្តរការី ពិតជាបានបង្ហាញឱ្យឃើញនូវភាពមានកម្រិតជាក់លាក់មួយចំនួន អាស្រ័យដោយវាអាចមានភាពយឺតយ៉ាវ និង មិនសូវមានប្រសិទ្ធភាពខ្ពស់ និង វាកាន់តែមានការលំបាកក្នុងការកសាងការជឿទុកចិត្ត ទំនាក់ទំនង និងការយោគយល់រវាងភាគី។



ផ្ទះថ្មីដែលកំពុងសាងសង់នៅឯសហាគមន៍អភិវឌ្ឍន៍មានជ័យ

## ផ្ដោតការយកចិត្តទុកដាក់ ប៉ុន្តែត្រូវប្រុងប្រយ័ត្ន ចំពោះហេតុការណ៍ខាងក្រៅ

ភាគីនៅក្នុងករណីនេះ មានបំណងដោះស្រាយបញ្ហាទាក់ទងនឹងអាកាសយានដ្ឋានខេត្តព្រះសីហនុ ស្របពេលដែលកំពុងមានកិច្ចខិតខំដោះស្រាយផលប៉ះពាល់ជាច្រើនដទៃទៀត ទាក់ទងទៅនឹងការអភិវឌ្ឍន៍ ដែលកំពុងមានភាពចម្រូងចម្រាសក្នុងប្រទេសកម្ពុជា។ ហេតុការណ៍ខាងក្រៅទាំងនេះហួសពីសមត្ថភាពគ្រប់គ្រងរបស់ការិយាល័យ CAO ព្រមទាំងភាគី ហើយវាអាចមានផលប៉ះពាល់អវិជ្ជមានជាសក្ដានុពល ទៅលើដំណើរការដោះស្រាយវិវាទ។

ឧទាហរណ៍ រយៈពេល២-៣ខែ មុនពេលដែលពាក្យបណ្ដឹងត្រូវបានផ្ញើទៅការិយាល័យ CAO មានពាក្យបណ្ដឹងចំនួន៣ទៀត ត្រូវបានដាក់ជូនទៅគណៈកម្មការអធិការកិច្ចរបស់ធនាគារពិភពលោក និងការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស នៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ ពាក្យបណ្ដឹងដែលបានដាក់ទៅគណៈកម្មការ

អធិការកិច្ចរបស់ធនាគារពិភពលោក ទាក់ទងទៅនឹងគម្រោងគ្រប់គ្រង និង រដ្ឋបាលដីធ្លីរបស់ធនាគារពិភពលោក និង ការដោះស្រាយផលប៉ះពាល់សម្រាប់ប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍បឹងកក់។ ពាក្យបណ្ដឹងអំពីការដោះស្រាយផលប៉ះពាល់ចំនួន២ទៀត ទាក់ទងនឹងគម្រោងធនាគារអភិវឌ្ឍន៍អាស៊ីចំនួន២ដោយឡែកពីគ្នា ៖ គម្រោងផ្លូវជាតិដែលភ្ជាប់រាជធានីភ្នំពេញ ទៅទីក្រុងហូជីមិញ និង គម្រោងស្ដារផ្លូវរថភ្លើងក្នុងមហាអនុតំបន់ទន្លេមេគង្គ (GMS)។ ករណីទាំងនេះអាចមានផលប៉ះពាល់អវិជ្ជមានជាសក្ដានុពលទៅលើកិច្ចខិតខំរបស់ភាគីនៅក្នុងដំណើរការដោះស្រាយវិវាទបែបសហការ ដែលដឹកនាំដោយការិយាល័យ CAO។

ដូច្នេះ រាល់ការពិភាក្សាអំពីបញ្ហាដែលទាក់ទងទៅនឹងការដោះស្រាយផលប៉ះពាល់នៅក្នុងប្រទេសកម្ពុជា បានធ្វើឡើងជាមួយនឹងភាពតានតឹងជាសក្ដានុពល ការយល់ច្រឡំជាសក្ដានុពល ការបង្កប់អត្ថន័យគោលនយោបាយ និង បញ្ហានយោបាយយ៉ាងទូលំទូលាយ និងការយល់ឃើញថាមានបង្កប់របៀបវារៈដទៃទៀតនៅក្នុងបញ្ហាទាំងនោះ ព្រមទាំងបញ្ហាដទៃទៀត។ ចំណុចនេះ ទាមទារឱ្យមានការអត់ធ្មត់ និងការតាំងចិត្ត ក្នុងចំណោមភាគីទាំងអស់ដែលធ្វើការងារជាមួយការិយាល័យ CAO នៅក្នុងករណីនេះ។ ក្រុមការងារនៃការិយាល័យ CAO និងជាពិសេស អ្នកសម្របសម្រួលក្នុងស្រុក បានធ្វើការងារដោយភាពឈ្លៀសវៃ ដើម្បីជួយដល់ភាគីពាក់ព័ន្ធទាំងអស់ឱ្យរក្សាបាននូវទស្សនវិស័យ និង ការផ្ដោតយកចិត្តទុកដាក់របស់ពួកគេ សំដៅសម្រេចឱ្យបាននូវលទ្ធផលមួយ ដែលអាចទទួលយកបាន ព្រមទាំងជាប្រយោជន៍សម្រាប់គ្រប់ភាគីទាំងអស់ដែលពាក់ព័ន្ធ។

## ទទួលស្គាល់ថា ភាគីអាចមានការលំបាក និងថ្លឹងថ្លែងទៅលើជម្រើសរបស់ពួកគេ

នៅដំណាក់កាលជាច្រើនក្នុងដំណើរការរបស់ការិយាល័យ CAO យ៉ាងហោចណាស់ មានភាគីមួយដែលមិនសប្បាយចិត្តចំពោះការឆ្លើយតប ឬ លទ្ធផលជាក់លាក់មួយ។ ការទាមទារដែលបានលើកឡើងមិនត្រូវបានបំពេញ។ សំនួរដែលបានសួរ នៅតែបន្តមិនទទួលបានចម្លើយ។ បុគ្គលខ្លះបានធ្វើសកម្មភាពមួយចំនួន ដែលពួកគេមានអារម្មណ៍ពីដំបូងថាមិនស្រណុកចិត្ត ឬ មានការប្រថុយប្រថាន[4]។ មានន័យថា នៅក្នុងដំណើរការទាំងមូល ការិយាល័យ CAO បានលើកទឹកចិត្តឱ្យភាគីបន្តសួរខ្លួនឯងថា "តើនេះនៅតែជាលទ្ធផលមួយដែលល្អជាងអ្វីដែលអ្នកអាចសម្រេចបានដែរឬទេ?" ចំណុចនេះ រមែងតែងតែជាការវាយតម្លៃមួយដែលលំបាក និង ពិបាកសម្រេចយ៉ាងខ្លាំងសម្រាប់ភាគីក្នុងការសម្រេចចិត្តនៅក្នុងដំណើរការដោះស្រាយវិវាទ ហើយធម្មជាតិបែបស្ម័គ្រចិត្តនៃដំណើរការនេះ អនុញ្ញាតឱ្យភាគីណាមួយអាចបញ្ឈប់ ឬ ដកខ្លួននៅដំណាក់កាលណាមួយក៏បាន។ នៅក្នុងករណីពហុភាគីមួយ ដូចជាករណីនេះ ភាគីក៏ជួបប្រទះទៅនឹងបញ្ហាប្រឈមមួយផងដែរ នៅពេលដែលភាគីមិនទទួលបាននូវរាល់ប្រយោជន៍ទាំងអស់ដែលពួកគេចង់បាន ប៉ុន្តែ បើទោះជាដូច្នេះក្ដី អ្នកចូលរួមភាគច្រើនចង់បន្តដំណើរការនេះ។

នៅក្នុងករណីនេះ ភាគីនៅតែបន្តមានភាពអត់ធ្មត់ និងឥតរួញរា។ ពួកគេខិតខំផ្ដោតទៅលើសេចក្ដីត្រូវការ និងគោលដៅសំខាន់បំផុតរបស់ពួកគេ ព្រមទាំងស្វែងរកវិធីដើម្បីសម្រេចឱ្យបាននូវសេចក្ដីត្រូវការ និងគោលដៅទាំងនោះ បើទោះបីជាមិនទទួលបានទាំងស្រុងនូវដំណោះស្រាយដ៏ល្អឥតខ្ចោះ ឬ ទទួលបាននូវអ្វីៗគ្រប់យ៉ាងដែលពួកគេចង់បានក៏ដោយ។

*ឯកសារដទៃទៀតដែលពាក់ព័ន្ធទៅនឹងករណីនេះ អាចរកមើលបាននៅក្នុងគេហទំព័ររបស់ការិយាល័យ CAO ៖* www.cao-ombudsman.org

[4] ឧទាហរណ៍ជាក់លាក់មិនត្រូវបានបញ្ចូលនៅត្រង់នេះដោយចេតនា ព្រោះតែកិច្ចការពារការសម្ងាត់។